ASIAN DECENT WORK DECADE 2006 2015

International Labour Organization
Organisation internationale du Travail
Organización Internacional del Trabajo

# អង្គការពលកម្មអន្តរជាតិនិងជនជាតិដើមភាគតិច
# គំរោងគាំទ្រជនជាតិដើមភាគតិចនៅកម្ពុជា

អង្គការពលកម្មអន្តរជាតិ( អាយឡូ) បានចាប់ផ្តើមធ្វើកិច្ចការជាយូរមកហើយក្នុងការការពារសិទ្ធិជនជាតិដើមភាគតិចនិងក្រុមកុលសម្ព័ន្ធ។ កិច្ចការទាំងនោះមាន ពីរ ដែលបំពេញគ្នាទៅវិញទៅមក :   ១-   ការបង្កើតឱ្យមានបទដ្ឋាន ( ស្តង់ដា)   ២-   ជំនួយបច្ចេកទេស

**សាវតា**   បញ្ហាមុនដំបូងដែលអាយឡូធ្វើដំបូងគេគឺផ្តោតលើស្ថានភាពកម្មករកម្មការនីនៅជនបទក្នុងទសវត្ស ១៩២០ ។មានកម្មករជាជនជាតិដើមនិងកុលសម្ព័ន្ធជាច្រើននៅក្នុងចំណោមកម្មករទាំងនោះ ។ នៅចន្លោះឆ្នាំ ១៩៣៦ និង ១៩៥៧ អាយឡូបានអនុម័តអនុសញ្ញាជាច្រើនដើម្បីការពារកម្មករទូទៅរួមទាំងអនុសញ្ញាមួយចំនួនដែលការពារកម្មករជាជនជាតិដើម និង ក្រុមកុលសម្ព័ន្ធ ។ អនុសញ្ញាទាំងនេះកំណត់នូវបញ្ហាដូចជាការជ្រើសរើសកម្មករ កិច្ចសន្យាការងារ និង ការងារដោយបង្ខំ ។ អនុសញ្ញាលេខ ១៦៩ បានមកពីការសើរើឡើងវិញនូវអនុសញ្ញាលេខ ១០៧ ដែលធ្វើឱ្យមានការផ្លាស់ប្តូរវិធីសាស្ត្រការងារពាក់ពន្ធ័នឹងជនជាតិដើមនិងក្រុមកុលសម្ពន្ធ័ ។ ការការពារនៅតែជាទិសដៅចម្បងក៏ប៉ុន្តែត្រូវតែមានមូលដ្ឋានលើការគោរពវប្បធម៌របៀបរបបរស់នៅខុសគ្នា ប្រពៃណីនិងទំនៀមទម្លាប់របស់គាត់ ។ កិច្ចការទាំងនេះក៏មានមូលដ្ឋាននៅលើជំនឿរបស់យើងថា ជនជាតិដើម និង ក្រុមកុលសម្ពន្ធ័មានសិទ្ធិបន្តរស់រានដោយរក្សាបាននូវអត្តសញ្ញាណនិងសិទ្ធិសម្រេចលើវិធីនិងល្បឿននៃការអភិវឌ្ឍន៍របស់ខ្លួន ។



អនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ ១៦៩ ស្តីពីជនជាតិដើមភាគតិចនិងក្រុមកុលសម្ពន្ធ័ ជាលិខិតូបករណ៍តែមួយគត់ជាអន្តរជាតិដែលចងកាតព្វកិច្ច ដែលមានគោលបំណងជាក់លាក់ក្នុងការការពារសិទ្ធិរបស់ពលរដ្ឋទាំងនោះ ហើយហួសពីចំនួននៃការផ្តល់សច្ចាប័ន អនុសញ្ញានេះគឺជាសំណុំគោលការណ៍មគ្គុទ្ទេសន៍ (នាំផ្លូវ) និង ជាឧបករណ៍សំរាប់ដោះស្រាយបញ្ហាជាច្រើនដែលជួបប្រទះដោយជនជាតិដើម ។ បទពិសោធន៏របស់យើងបង្ហាញថា អនុសញ្ញានេះជាឧបករណ៍សំរាប់បង្កាមិនឱ្យមានទំនាស់ កាត់បន្ថយភាពក្រីក្រ អភិបាលកិច្ចល្អ និង ការពិភាក្សាគ្នានៅក្នុងកិច្ចការជាច្រើនទៀត ។

## អាយឡូ (ILO) និងសហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា

ចាប់តាំងពីឆ្នាំ ២០០៥ កិច្ចការនិងអាណត្តិផ្អែកលើគោលការណ៍នៃអនុសញ្ញាលេខ ១៦៩ គំរោងគាំទ្រជនជាតិដើមភាគតិចនៅកម្ពុជា បាននិងកំពុងលើកកំពស់ឱ្យមានការចូលរួមនិងការពិគ្រោះយោបល់របស់សហគមន៍ជនជាតិដើមភាគតិច នៅក្នុងសេចក្តីសម្រេចណាមួយដែលប៉ះពាល់ផ្ទាល់ដល់ពួកគាត់ក្នុងគោលបំណងដើម្បីកាត់បន្ថយភាពក្រីក្រនិងតាមវិធីសាស្ត្រដែលគោរពដល់វប្បធម៌ របៀបរបបរស់នៅ ប្រពៃណីនិងទំនៀមទម្លាប់របស់គាត់។ គំរោងនេះអនុវត្តការងាររបស់ខ្លួននៅក្នុងខេត្តចំនួន ៣ ដែលមានចំនួនពលរដ្ឋជនជាតិដើមច្រើន គឺខេត្តរតនគីរី ខេត្តមណ្ឌលគីរី និងខេត្តព្រះវិហារ។

**មូលនិធិ** : ភ្នាក់ងារប្រទេសដាណឺម៉ាកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ **(DANIDA) and ILO-PRO 169 Geneva, Switzerland**

**សកម្មភាពចម្បង** :

១- ពង្រឹងសម្ថតភាពអំពីបញ្ហាជនជាតិដើមភាគតិចនិងសិទ្ធិរបស់គាត់ ដល់អង្គការជនជាតិដើមភាគតិច អង្គការក្នុងស្រុក មន្ត្រីពាក់ពន្ធ័ និងអ្នកឯទៀតដែលមានចំណាប់អារម្មណ៍ អំពីប្រធានបទដែលទាក់ទងនឹងបញ្ហានិងសិទ្ធិរបស់គាត់ ។

២- ជួយការងារចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចជានីតិបុគ្គលដើម្បីឈានទៅដល់ការចុះបញ្ជីដីកម្មសិទ្ធិសមូហភាព ដែលជាជំហានទៅរកការការពារនិងការគ្រប់គ្រងដីសហគមន៍តាមច្បាប់របស់ប្រទេសកម្ពុជានិងស្តង់ដាអន្តរជាតិ ។







ទំនាក់ទំនង :

Tel: (855) 23 220 817.
Mobile: (855) 12 8902 89.
Fax: (855) 23 221 536
Email: sophorns@ilo.org
www.ilo.org/indigenous